# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ១

បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# អាជ្ញាធរជាតិដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ

រៀបចំដោយៈ

-ឯកឧត្តម **ញាន វណ្ណៈ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌

-ឯកឧត្តម **តាន់ហ៊ាង ដាវ័ណ្ណ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌

## សេចក្តីផ្តើម

វិវាទរវាងបុគ្គល និងបុគ្គល អាចត្រូវបានដោះស្រាយដោយយន្តការតុលាការ ឬយន្តការផ្សេងទៀតក្រៅពីយន្តការតុលាការ។ ការដោះស្រាយតាមរយៈយន្តការផ្សេងក្រៅពីយន្តការតុលាការនេះ ត្រូវបានកំណត់ថាជា "**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**"។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះអាចធ្វើឡើងតាមវិធីសាស្ត្រផ្សេងៗដែលរួមមានការចរចា[1]ការផ្សះផ្សា ឬ **ការសម្រុះសម្រួល**[2] និង **អាជ្ញាកណ្តាល** ឬ **មជ្ឈត្តការ**[3] ។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រមួយចំនួនជាវិធីសាស្ត្រដែលដំណោះស្រាយចំពោះវិវាទអាចទទួលបាន ដោយផ្អែកទាំងស្រុងលើការព្រមព្រៀងរបស់ភាគីវិវាទ ទោះដោយមាន ឬគ្មានជំនួយពីភាគីទី៣ ក៏ដោយ (*ការចរចា, ការផ្សះផ្សាឬការសម្រុះសម្រួល*)ហើយវិធីសាស្ត្រមួយចំនួនទៀតជាវិធីសាស្ត្រដែលដំណោះស្រាយទទួលបាន ដោយមានការវិនិច្ឆ័យសម្រេចសេចក្តីតាមរបៀបនៃការកាត់ក្តី(*អាជ្ញាកណ្តាល*

1. ***ការចរចា*** (negotiation) ជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីវិវាទឬតាមរយៈអ្នកតំណាងរបស់ភាគីវិវាទ។ភាគីលើកសំណើដំណោះស្រាយជាមួយគ្នាទៅវិញទៅមករហូតដល់សម្រេចបាននូវការព្រមព្រៀងគ្នាលើសំណើដំណោះស្រាយណាមួយ ដែលនាំឱ្យឈានដល់ការបញ្ចប់វិវាទ។ ជាទូទៅ ការចរចានេះ គឺជាជម្រើសដំបូងដ៏ល្អបំផុត និងវិធីសាស្ត្រដែលមានការពេញនិយមបំផុត ដោយសារជាវិធីសាស្ត្រដែលលឿន ហើយភាគីគ្រប់គ្រងបានទាំងស្រុងលើដំណើរការចរចា, លទ្ធផលនៃការចរចាមានភាពបត់បែនខ្ពស់ទៅតាមឆន្ទៈរបស់ភាគីវិវាទនិងងាយស្រួលក្នុងការអនុវត្តព្រមទាំងអាចរក្សាបាននូវការសម្ងាត់របស់ភាគី។ជាធម្មតាមុននឹងសម្រេចប្តឹងផ្តល់គ្នាទៅយន្តការផ្សេងៗសម្រាប់វិនិច្ឆ័យកាត់ក្តី ភាគច្រើនភាគីតែងព្យាយាមសាកល្បងចរចាគ្នាជាមុនសិន ទោះដោយផ្ទាល់ក្តី ទោះតាមរយៈអ្នកតំណាងក្តី។
2. ***ការផ្សះផ្សា*** (conciliation) ***ឬការសម្រុះសម្រួល*** (mediation) ជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទតាមរយៈការចរចាគ្នា ដោយមានជំនួយពីភាគីទី៣ ដែលត្រូវតែមានភាពអព្យាក្រឹតចំពោះភាគីទាំងសងខាង។ ភាគីទី៣ ដែលជាអ្នកគ្រប់គ្រងដំណើរការផ្សះផ្សា ឬសម្រុះសម្រួលវិវាទ មិនមានសិទ្ធិអំណាចចាប់បង្ខំឱ្យភាគីវិវាទទទួលយកនូវដំណោះស្រាយណាមួយនោះទេ។ រាល់ការសម្រេចនៅតែជាសិទ្ធិអំណាចរបស់ភាគីវិវាទ។ ភាគីទី៣ ជាអ្នកសម្របសម្រួលឱ្យភាគីវិវាទជួបជជែកចរចាគ្នា ហើយភាគីទី៣ អាចមានតួនាទីសកម្ម ឬមិនសូវសកម្ម អាស្រ័យទៅលើថាតើវិធីសាស្ត្រនៃការដោះស្រាយនោះជាការផ្សះផ្សាវិវាទ ឬជាសម្រុះសម្រួលវិវាទ។ប៉ុន្តែលើការជាក់ស្តែងពាក្យ ការផ្សះផ្សានិងការសម្រុះសម្រួលនេះត្រូវបានប្រើឡាយឡំគ្នា ទាំងក្នុងក្របខ័ណ្ឌច្បាប់ ទាំងក្នុងការអនុវត្តជាក់ស្តែង។
3. ***មជ្ឈត្តកម្ម ឬ អាជ្ញាកណ្តាល***(arbitration) គឺជាកិច្ចដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយប្រភេទ ដែលធ្វើឡើងដោយភាគីទីបីជាអ្នកអព្យាក្រឹត (មជ្ឈត្តករ ឬអាជ្ញាកណ្តាល) ដែលមានសិទ្ធិសម្រេច និងវិនិច្ឆ័យរកខុសត្រូវចំពោះវិវាទ (ការកាត់ក្តី) បន្ទាប់ពីបានពិនិត្យអង្គហេតុ អង្គច្បាប់ ភស្តុតាង និងស្តាប់ការជជែកវែកញែកពីភាគីវិវាទរួចមក។ មជ្ឈត្តកម្ម ឬអាជ្ញាកណ្តាល នេះ តែងត្រូវបានប្រើប្រាស់សម្រាប់វិវាទដែលមានលក្ខណៈស្មុគស្មាញ ជាអាទិ៍ វិវាទការងាររួម និងវិវាទពាណិជ្ជកម្ម ជាដើម។

ការងារ និងមជ្ឈត្តការពាណិជ្ជកម្ម)។ ការដោះស្រាយវិវាទតាមរយៈយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម ហើយបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ឡើងៗនៅក្នុងប្រព័ន្ធយុត្តិធម៌ ទាំងនៅក្នុងប្រព័ន្ធច្បាប់ Civil Law, ប្រព័ន្ធច្បាប់ Common Law និងទាំងប្រព័ន្ធច្បាប់ផ្សេងទៀត ដោយមូលហេតុសំខាន់ៗ ជាអាទិ៍៖ (១)-ជាវិធីសាស្ត្រដោះស្រាយវិវាទ បានឆាប់រហ័ស ជាងការដោះស្រាយតាមប្រព័ន្ធតុលាការដែលអាចត្រូវចំណាយពេលជាច្រើនក្នុងការជំនុំជម្រះក្តីតាំងពីសាលាដំបូងដល់តុលាការកំពូល,(២)-ដំណោះស្រាយតាមយន្តការក្រៅប្រព័ន្ធតុលាការអាចមានភាពបត់បែន និងអាចទទួលយកបានដោយភាគីវិវាទ និងអាចរក្សាបាននូវទំនាក់ទំនងរវាងភាគីវិវាទ ខុសពីការវិនិច្ឆ័យសម្រេចសេចក្តីដែលតែងនាំឱ្យមានភាគីម្ខាងចាញ់ក្តី និងភាគីម្ខាងទៀតឈ្នះក្តី ហើយភាគីវិវាទមិនអាចរក្សាបាននូវទំនាក់ទំនងល្អរវាងគ្នានឹងគ្នាបន្តទៀត, (៣)-ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីវិវាទអាចមិនចំណាយប្រាក់ ឬចំណាយតិចជាងការចំណាយសម្រាប់ការដោះស្រាយក្នុងប្រព័ន្ធតុលាការដូចសុភាសិតខ្មែរពោលថា “**ធ្ងន់នឹងថ្ម ក្រនឹងក្តី**” (ចំណាយលើមេធាវីនៅគ្រប់ដំណាក់កាល, ចំណាយលើការធ្វើដំណើរចុះឡើងច្រើនដង ជាដើម), (៤)-ទីតាំងរបស់សាលាជម្រះក្តីអាចនៅឆ្ងាយពីប្រជាពលរដ្ឋ ពិសេស សម្រាប់ប្រជាពលរដ្ឋក្រីក្រ ឬរស់នៅតំបន់ដាច់ស្រយាលដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមកប្តឹងផ្តល់គ្នានៅតុលាការ,(៥)-វិវាទក្នុងគ្រួសារដែលគួរមានការសម្រុះសម្រួលឱ្យបានច្រើនជាមុន ដើម្បីរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារ រក្សាបាននូវទំនាក់ទំនងញាតិ និងការពារផលប្រយោជន៍របស់កូន, និង (៦)-ចំនួនសំណុំរឿងនៅតុលាការ តែងមានការកើនឡើងជាបន្តបន្ទាប់ ប៉ុន្តែ ចំនួនចៅក្រមជម្រះក្តីនៅមិនទាន់គ្រប់គ្រាន់ដែលធ្វើឱ្យមាននិន្នាការក្នុងការបញ្ជូន ឬតម្រូវឱ្យវិវាទដែលមានលក្ខណៈតូចតាចត្រូវស្វែងរកការផ្សះផ្សាឬការសម្រុះសម្រួលជាមុនសិនដើម្បីទុកលទ្ធភាពឱ្យចៅក្រមផ្តោតការយកចិត្តទុកដាក់លើវិវាទធំៗដែលមានលក្ខណៈស្មុគស្មាញ និងមិនអាចសម្រុះសម្រួលគ្នាបាន។

ផ្អែកលើមូលដ្ឋាន និងសារសំខាន់ខាងលើ ទើបរាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាសសរស្តម្ភមួយដ៏សំខាន់នៃកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា[4]។ ជាលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ,

4.ឯកសារ “ការកែទម្រង់ច្បាប់ និងតុលាការ”” ឆ្នាំ២០០៣ ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ ហើយ “កម្មវិធី សកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ”” ត្រូវបាន,អនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៥។ ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ច្បាប់ និងតុលាការ មាន៧ រួមមាន៖ (១)-ពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល, (២)-ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់, (៣)-ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការកាន់តែប្រសើរឡើង, (៤)-ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ (៥)-ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ, (៦)-បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង (៧)-ពង្រឹង ស្ថាប័នវិស័យច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច។

យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗត្រូវបានបង្កើតឡើងជាផ្លូវការជាបន្តបន្ទាប់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តនានា។អាជ្ញាកណ្តាលការងារដែលមានសមត្ថកិច្ចដោះស្រាយវិវាទការងារដែលការផ្សះផ្សាពុំបានសះជាត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ និងប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលឆ្នាំ២០០២[5]។ បន្ទាប់មក នៅឆ្នាំ២០០៦ មជ្ឈត្តការផ្តែកពាណិជ្ជកម្មត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីមជ្ឈត្តការផ្តែកពាណិជ្ជកម្មសម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្មស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទ[6]។ ក្រៅពីយន្តការទាំង ២ នេះ មានយន្តការផ្សេងទៀតដែលមានលក្ខណៈរដ្ឋបាល ត្រូវបានបង្កើតឡើងនៅតាមវិស័យនានាផងដែរ ជាអាទិ៍ (១)-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដី សម្រាប់ដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីដីធ្លី ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១, (២)-គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម សម្រាប់ផ្សះផ្សាទំនាស់ដែលអាចកើតមានក្នុងអំឡុងពេលអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យា(កិច្ចសន្យាផលិតកម្មកសិកម្ម) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យឆ្នាំ២០១១ ស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យា, (៣)-មណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រែក្លាយទៅជាការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានស្ថិតក្រោមរចនាសម្ព័ន្ធរដ្ឋបាលក្រុងស្រុកខណ្ឌនៅទូទាំងប្រទេសកម្ពុជានិង(៤)-មេឃុំ-ចៅសង្កាត់និងក្រុមប្រឹក្សាឃុំ-សង្កាត់សម្រាប់ដោះស្រាយសម្រុះសម្រួលវិវាទគ្រួសារ និងវិវាទរដ្ឋប្បវេណីនៅក្នុងមូលដ្ឋាន។យន្តការទាំងនេះបាននិងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែ ពេលខ្លះ វិវាទមួយចំនួនដែលត្រូវបានដោះស្រាយបញ្ចប់ដោយយន្តការទាំងនេះបានលាប់ឡើងវិញនៅពេលដែលភាគីម្ខាងមិនគោរពតាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នាដែលមានតម្លៃត្រឹមជាកិច្ចព្រមព្រៀង និងមិនមានអានុភាពអនុវត្តតាមផ្លូវតុលាការ ហើយពេលខ្លះ ភាគីមិនសុខចិត្តនៅតែមានសិទ្ធិក្នុងការប្តឹងតវ៉ាបន្តទៅយន្តការតុលាការ។ទន្ទឹមនេះយន្តការមួយចំនួនដែលត្រូវបានបង្កើតឡើងមានសមត្ថកិច្ចដោះស្រាយតែវិវាទមួយចំនួនប៉ុណ្ណោះ ដូចជា វិវាទដីធ្លី វិវាទការងារ ឬវិវាទពាណិជ្ជកម្ម ដែលធ្វើឱ្យវិវាទទូទៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមិនមានយន្តការជាក់លាក់ណាមួយអាចទទួលបន្ទុកដោះស្រាយប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។

5. ប្រកាសលេខ ៣៣៨ សកបយ. ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
6. ច្បាប់ស្តីពីមជ្ឈត្តការផ្តែកពាណិជ្ជកម្ម ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦។

ផ្អែកលើការវាយតម្លៃនេះ និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, **"អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ"** ហៅកាត់ថា **"អ.ជ.ក."** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យឆ្នាំ២០២៣[7]។ យោងតាមមាត្រា១ នៃព្រះរាជក្រឹត្យនេះ, អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះគឺជា"*យន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទនៅព្រះរាជាណាចក្រកម្ពុជាសំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលផ្សះផ្សាក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី បង្កិតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ*"។ ផ្អែកតាមមាត្រានេះ យើងអាចកត់សម្គាល់បាននូវចំណុចសំខាន់ចំនួន ២ គឺ៖

- យន្តការ **អ.ជ.ក.** នេះ ជាយន្តការថ្មីមួយដែលបំពេញបន្ថែមឱ្យយន្តការដោះស្រាយវិវាទដែលមានស្រាប់ និងមិនជំនួសយន្តការដែលមានស្រាប់នោះទេ។ ការបង្កើតយន្តការនេះ នឹងផ្តល់ជាជម្រើសថ្មីមួយដែល"***កាន់តែងាយស្រួល, កាន់តែសម្បូរបែប, កាន់តែខិតជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងកាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ***" ជូនប្រជាពលរដ្ឋ ដែលមានបំណងស្វែងរកការសម្រុះសម្រួលដោះស្រាយបញ្ចប់វិវាទរបស់ខ្លួនឱ្យបានឆាប់។ ប្រជាពលរដ្ឋមានជម្រើសក្នុងការប្រើប្រាស់យន្តការថ្មីនេះ ឬយន្តការដែលមានស្រាប់ ដើម្បីដោះស្រាយវិវាទរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំ។
- ការបង្កើតនូវ **អ.ជ.ក.** មានគោលបំណងសំខាន់ចំនួន ៣។ ទី១-គឺការជួយកាត់បន្ថយការកកស្ទះសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី។ ទី២-គឺការបង្កិតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទី៣-គឺការសម្រុះសម្រួលដោះស្រាយវិវាទដោយ **អ.ជ.ក.** នឹងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។

តើ **អ.ជ.ក.** ត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ? និងតើការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ដំណើរការយ៉ាងដូចម្តេច, ត្រូវគោរពតាមគោលការណ៍អ្វីខ្លះ ហើយលទ្ធផលសះជានៃកាសម្រុះសម្រួលផ្សះផ្សាវិវាទនេះមានអានុភាពគតិយុត្តយ៉ាងដូចម្តេច?

## I- ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការបង្កើតនូវអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានសំខាន់ៗចំនួន ៣ គឺ៖ (១)-មូលដ្ឋានផ្អែកគោលនយោបាយ, (២)-មូលដ្ឋានផ្អែកច្បាប់ និង (៣)-មូលដ្ឋានផ្អែកសង្គម។

7.ព្រះរាជក្រឹត្យលេខនស/រកត/១១២៣/២៣៨១ចុះថ្ងៃទី២ខែវិច្ឆិកាឆ្នាំ២០២៣ស្តីពីការបង្កើតការរៀបចំនិងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

## ១-មូលដ្ឋានផ្អែកគោលនយោបាយ

លើទិដ្ឋភាពគោលនយោបាយ, ព្រះរាជក្រឹត្យបង្កើត **អ.ជ.ក.** ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានសំខាន់ចំនួន ២ គឺៈ **(ទី១)-"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា និង **(ទី២)-"វិធានការគន្លឹះជាអាទិភាពទាំង ៥"** របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដែលទាំង"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" ទាំង **"វិធានការគន្លឹះជាអាទិភាពទាំង៥"** នេះត្រូវបាន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ។

ផ្អែកតាម **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"**, សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភានេះ, រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅតែបានបន្តចាត់ទុក **"ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ជាអាទិភាពមួយដ៏សំខាន់របស់ខ្លួន សំដៅពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងចក្ខុវិស័យដើម្បីពង្រឹង និងលើកកម្ពស់ **"គោលការណ៍នីតិរដ្ឋ"** និង **"យុត្តិធម៌នៅក្នុងសង្គម"** ដែលជាកត្តាសំខាន់ និងចាំបាច់ក្នុងការរួមចំណែកធានាថែរក្សាស្ថិរភាពសង្គម សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ **"ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ត្រូវបានរៀបចំជាមុំមួយក្នុងចំណោមមុំទាំង៥ដែលបង្កើតបានជាស្នូលនៃ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** របស់រាជរដ្ឋាភិបាល ហើយចំណុចទី៦ ក្នុងមុំទី៤ នៃស្នូល **"យុទ្ធសាស្ត្របញ្ចកោណ"** នេះ, រាជរដ្ឋាភិបាលបានដាក់ចេញជាទិសដៅអាទិភាពគឺការរៀបចំនូវក្របខ័ណ្ឌច្បាប់ និងយន្តការសម្រុះសម្រួល និងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ, បង្កិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួលនិងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនិងធានាបាននូវបរិយាកាសសន្តិភាពនិយម និងភាពសុខដុមរមនាក្នុងសង្គមជាតិ។

ទន្ទឹមនេះ, បន្ថែមលើ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"**, នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកដំបូង, **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានប្រកាសដាក់ចេញនូវវិធានការគន្លឹះជាអាទិភាពចំនួន៥ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដោយត្រូវសម្រេចឱ្យចេញជាលទ្ធផល នៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភានេះ ដោយក្នុងនោះ **"ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌"** គឺជាអាទិភាពដ៏សំខាន់មួយក្នុងចំណោមវិធានការគន្លឹះទាំង ៥ នេះ ហើយ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានសម្រេចប្រគល់ភារកិច្ចនេះ ជូនក្រសួងយុត្តិធម៌ ក្នុងការរៀបចំផែនការសកម្មភាពជាក់ស្តែង សំដៅធ្វើយ៉ាងណា

សម្រេចឱ្យបាននូវកិច្ចការអាទិភាពសំខាន់ៗចំនួន ៣ ដែលក្នុងនោះរួមមានៈ **(ទី១)**-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័សជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន, **(ទី២)**-ការជំរុញនិងការពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស និង **(ទី៣)**-ការត្រួតពិនិត្យនិងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការសំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ផ្អែកតាម **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** និង **"វិធានការគន្លឹះ"** ខាងលើនេះ, ជាទិសដៅការងារទៅមុខ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា នឹងត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើ **"សសរស្តម្ភ"** ចំនួន ២ គឺ **(សសរស្តម្ភទី១)**-ការកែទម្រង់ប្រព័ន្ធតុលាការ សំដៅខិតខំធ្វើឱ្យប្រសើរឡើងជាលំដាប់ជាបន្តទៀត នូវគុណភាព និងប្រសិទ្ធភាព ទាំងលើការផ្តល់សេវាយុត្តិធម៌ប្រកបដោយភាពឆាប់រហ័ស ទាំងលើគុណភាពនៃយុត្តិធម៌ប្រកបដោយភាពសុក្រឹត និងភាពត្រឹមត្រូវ និង **(សសរស្តម្ភទី២)**-ការកែទម្រង់ប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅបង្កិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួល និងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន,ជួយសម្រុះសម្រួលផ្សះផ្សាដោះស្រាយបញ្ចប់វិវាទឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយមក្នុងសង្គមកម្ពុជា។

ហេតុដូចនេះ លើទិដ្ឋភាពនយោបាយ ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនាពេលនេះ គឺជា **"ការបោះជំហានថ្មីមួយ"** ដ៏មានសារសំខាន់សម្រាប់ការកែទម្រង់យន្តការដោះស្រាយវិវាទនៅកម្ពុជាឱ្យមានភាពកាន់តែសម្បូរបែបនិងងាយស្រួលប្រើប្រាស់ហើយអាចឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ពិសេសនៅតាមមូលដ្ឋានស្របតាមទិសដៅនិងចក្ខុវិស័យនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលព្រមទាំងវិធានការគន្លឹះអាទិភាពទាំង ៥ ចំណុចរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលបានប្រកាសដាក់ចេញជាផ្លូវការក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ។

## ២-មូលដ្ឋានផ្នែកច្បាប់

លើទិដ្ឋភាពច្បាប់, ការដោះស្រាយវិវាទអាចប្រព្រឹត្តទៅទាំងតាមប្រព័ន្ធតុលាការ ទាំងតាមយន្តការក្រៅប្រព័ន្ធតុលាការ លើកលែងតែករណីខ្លះដែលច្បាប់កំណត់ជាសមត្ថកិច្ចផ្តាច់មុខរបស់ស្ថាប័នតុលាការ ដូចជាករណីរឿងព្រហ្មទណ្ឌជាដើម។វិធីសាស្ត្រនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានក្លាយជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ដូចនេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពុំមែនជារឿងថ្មីនោះទេ។ដូចបានគូសបញ្ជាក់ពីខាងដើមយន្តការ

ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាច្រើនត្រូវបានអនុញ្ញាតដោយច្បាប់។

ចំពោះវិធីសាស្ត្រដែលត្រូវបាននិយមយកមកប្រើ ដើម្បីដោះស្រាយវិវាទនៅក្នុងសង្គមនីតិរដ្ឋ មាន ២ សំខាន់ គឺ ៖ **“វិធីកាត់ក្តី”** និង **“វិធីសម្រុះសម្រួលផ្សះផ្សាវិវាទ”**។ វិធីសាស្ត្រទាំងពីរនេះ ត្រូវបានច្បាប់អនុញ្ញាតឱ្យប្រើ ទាំងក្នុងយន្តការតុលាការ ទាំងក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។សម្រាប់ប្រព័ន្ធតុលាការ, **“ការកាត់ក្តី”** គឺជាវិធីសាស្ត្រដែលត្រូវបានប្រើជាទូទៅដោយតុលាការដើម្បីដោះស្រាយវិវាទ។ របៀបនៃការដោះស្រាយវិវាទដោយការសម្រេចសេចក្តីនេះ ក៏ត្រូវបានទទួលស្គាល់ផងដែរ ដល់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធ ហើយដែលគេស្គាល់ជាទូទៅ គឺ **“យន្តការមជ្ឈត្តការ”** ឬ **“យន្តការអាជ្ញាកណ្តាល”**។ ការដោះស្រាយវិវាទដោយ **“ការកាត់ក្តី”** នេះ ថ្វីត្បិតតែជាទូទៅនឹងផ្តល់លទ្ធផលជាដំណោះស្រាយឱ្យមានភាគីម្ខាងជាភាគីឈ្នះក្តី ហើយភាគីម្ខាងទៀតជាភាគីចាញ់ក្តីក៏ពិតមែន ប៉ុន្តែវិធីដោះស្រាយវិវាទបែបនេះគឺមានភាពចាំបាច់ដើម្បីធានាការពារសិទ្ធិស្របច្បាប់របស់បុគ្គលនៅក្នុងសង្គម ហើយផ្តល់យុត្តិធម៌ទៅដល់បុគ្គលរងគ្រោះ ដែលសិទ្ធិស្របច្បាប់របស់ខ្លួនត្រូវបានរំលោភបំពាន។ ទន្ទឹមនឹងរបៀបដោះស្រាយវិវាទដោយ **“ការកាត់ក្តី”**, ច្បាប់ក៏អនុញ្ញាតឱ្យមានវិធីដោះស្រាយវិវាទដោយ **“ការសម្រុះសម្រួល ផ្សះផ្សា”** ផងដែរ ជាពិសេសសម្រាប់វិវាទក្នុងវិស័យមួយចំនួនដែលច្បាប់អនុញ្ញាត។ យោងតាមច្បាប់ជាធរមាន, ការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សាគ្នានេះ គឺត្រូវបានអនុញ្ញាតទាំងនៅក្នុងប្រព័ន្ធតុលាការ ទាំងនៅក្រៅប្រព័ន្ធតុលាការ។ លើសពីនេះ ចំពោះវិវាទមួយចំនួន ច្បាប់តម្រូវឱ្យមានការសម្រុះសម្រួលផ្សះផ្សាគ្នាជាមុន ទើបអាចឈានទៅរកការដោះស្រាយ តាមរយៈការកាត់ក្តី[៨]។

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ចៅក្រមក៏អាចធ្វើការសម្រុះសម្រួល និងផ្សះផ្សារវាងគូភាគី ដើម្បីបញ្ចប់វិវាទនៅក្នុងសំណុំរឿងរដ្ឋប្បវេណី ហើយការសម្រុះសម្រួលនេះ អាចធ្វើ ឡើងបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ យោងតាមមាត្រា១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, *នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ។ បន្ថែមពីនេះ មាត្រា២២០ នៃក្រមដដែលបានបញ្ញត្តិថាភាគីអាចធ្វើការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សាបាន។ ការផ្សះផ្សានេះអាចធ្វើនៅក្រៅទីតាំងតុលាការក៏បាន ប្រសិនបើតុលាការ*

8. នៅប្រទេសបារាំង ចាប់តាំងពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣, រាល់វិវាទទាំងឡាយណាដែលមានទឹកប្រាក់មិនលើសពី ៥០០០អឺរ៉ូ ភាគីចាំបាច់ត្រូវស្វែងរកដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាមុនសិន ទើបអាចប្តឹងទៅតុលាការបាន។ ប្រសិនបើភាគីប្តឹងទៅតុលាការមិនទាន់ស្វែងរកដំណោះស្រាយវិវាទក្រៅផ្លូវតុលាការជាមុននោះទេចៅក្រមត្រូវបដិសេធបណ្តឹងនោះតែម្តង។ក្នុងន័យនេះការស្វែងរកដំណោះស្រាយក្រៅប្រព័ន្ធតុលាការបានក្លាយជាកាតព្វកិច្ចសម្រាប់សំណុំរឿងដែលមានចំនួនទឹកប្រាក់តិច។ (Décret no 2023-357 du 11 mai 2023 relatif à la tentative préalable obligatoire de la médiation, de conciliation ou de procedure participative en matière civile).

*យល់ឃើញថាសមរម្យ។ ការផ្សះផ្សាដែលធ្វើឡើងដោយតុលាការ គឺមានតម្លៃគតិយុត្តរឹងមាំ ដោយហេតុថា* ***កំណត់ហេតុស្តីពីការសះជា*** *ដែលជាលទ្ធផលនៃការផ្សះផ្សាបញ្ចប់វិវាទដោយចៅក្រមមាន តម្លៃជាលិខិតអនុវត្ត*[9] *និងមានអានុភាពដូចសាលក្រមស្ថាពរ*[10]។ ប៉ុន្តែ, លើការជាក់ស្តែង, ការដោះស្រាយសំណុំរឿងដោយការសម្រុះសម្រួលផ្សះផ្សានេះមិនសូវត្រូវបានប្រើដោយចៅក្រមនោះទេដោយសារការសម្រុះសម្រួលវិវាទត្រូវការពេលវេលាច្រើនខណៈពេលដែលចៅក្រមត្រូវទទួលបន្ទុកដោះស្រាយសំណុំរឿងជាច្រើន។ ហេតុដូចនេះ ជាទូទៅ ការសម្រុះសម្រួលផ្សះផ្សាវិវាទតែងប្រព្រឹត្តទៅនៅក្រៅប្រព័ន្ធតុលាការ។ ផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធដោះស្រាយវិវាទដែលកំពុងអនុវត្តនៅក្នុងបណ្តាប្រទេសជាច្រើន ទាំងក្នុងតំបន់ និងពិភពលោក, វិធីដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សា គឺកំពុងទទួលបានការពេញនិយមកាន់តែច្រើនឡើងពីសំណាក់ភាគីវិវាទហើយយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះក៏ត្រូវបានលើកកម្ពស់ជាលំដាប់ ដោយរួមទាំងការបង្កើតឱ្យមានវិជ្ជាជីវៈច្បាប់ថ្មីមួយគឺ **"សន្ធានការី"** ដែលជាអ្នកជំនាញក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ។

## ៣-មូលដ្ឋានផ្នែកសង្គម

លើទិដ្ឋភាពសង្គម, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានឫសគល់ប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅនៅក្នុងបណ្តាប្រទេស និងវប្បធម៌ជាច្រើន។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺមានលក្ខណៈស្របទៅនឹងប្រពៃណីនៃការដោះស្រាយវិវាទនៅក្នុងសង្គមកម្ពុជាដែលជាទូទៅប្រជាពលរដ្ឋតែងប្រើយន្តការរដ្ឋបាលដោយប្តឹងទៅអាជ្ញាធរមូលដ្ឋានដូចជាមេភូមិ,មេឃុំ,អភិបាលស្រុក ឬអភិបាលខេត្តជាដើម ដើម្បីជួយដោះស្រាយវិវាទរបស់ពួកគាត់ ហើយវិធីសាស្ត្រក្នុងការដោះស្រាយវិវាទដែលល្អបំផុតតាមរយៈយន្តការរដ្ឋបាលនេះ គឺការសម្រុះសម្រួលផ្សះផ្សាវិវាទ ដើម្បីទទួលបាននូវដំណោះស្រាយមួយ ដែលជា **"ដំណោះស្រាយឈ្នះ-ឈ្នះ"** សម្រាប់ភាគីវិវាទដែលមានការពាក់ព័ន្ធ។

សម្រាប់សង្គមកម្ពុជាក្នុងយុគសម័យទំនើប, ការដោះស្រាយវិវាទដោយការសម្រុះសម្រួលផ្សះផ្សាគ្នា ដែលធានាបាននូវបរិយាកាសឈ្នះ-ឈ្នះសម្រាប់គូភាគីវិវាទ គឺមានមូលដ្ឋានគ្រឹះនៅក្នុង **"នយោបាយឈ្នះ-ឈ្នះ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលមិនមែនត្រឹមតែជាការដោះស្រាយវិវាទធម្មតានោះទេ ប៉ុន្តែ **"នយោបាយឈ្នះ-ឈ្នះ"** នេះគឺជារូបមន្តដ៏ស័ក្តិសិទ្ធិក្នុងការដោះស្រាយផ្សះផ្សាបាននូវការបែកបាក់ជាតិនិងការពន្លត់បានទាំងស្រុង

9. ចំណុច ឈ កថាខណ្ឌទី២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

10. មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា "ក្នុងករណីដែលមានការសះជាការលះបង់នូវការទាមទារ ឬការទទួល ស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ"" ។

នូវភ្លើងសង្គ្រាមដ៏រ៉ាំរ៉ៃអស់ជាងពីរទសវត្សរ៍នៅកម្ពុជា ហើយបាននាំមកនូវការបង្រួបបង្រួមជាតិ, ការឯកភាពជាតិនិងសន្តិភាពពេញបរិបូរណ៍ជូនជាតិមាតុភូមិនិងប្រជាជនកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន ហើយ **សម្តេចតេជោ ហ៊ុន សែន** ត្រូវបានប្រជាជនកម្ពុជាចាត់ទុក និងប្រសិទ្ធនាមជា **“បិតាសន្តិភាពរបស់កម្ពុជា”**។

## II- របបគតិយុត្តនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ដ.ក

(១)-តើវិវាទណាខ្លះអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាក្នុងក្របខ័ណ្ឌ **អ.ដ.ក.**? (២)-តើការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ដ.ក.** ត្រូវផ្អែកលើគោលការណ៍គ្រឹះអ្វីខ្លះ? និង(៣)-តើលទ្ធផលជោគជ័យនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ អ.ដ.ក. មានអានុភាពគតិយុត្តយ៉ាងដូចម្តេច?

### ១- វិវាទដែលជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាដោយ អ.ដ.ក.

ប្រភេទនៃវិវាទដែលអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាក្នុងក្របខ័ណ្ឌ**អ.ដ.ក.** ត្រូវបានកំណត់នៅក្នុងមាត្រា២ និងមាត្រា១១ នៃព្រះរាជក្រឹត្យបង្កើត **អ.ដ.ក.**។ ផ្អែកតាមមាត្រាទាំង ២ នេះ, វិវាទដែលជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា ក្នុងសមត្ថកិច្ចរបស់ **អ.ដ.ក.** រួមមានវិវាទរដ្ឋប្បវេណីវិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀតដែលផ្អែកតាមច្បាប់ ការបញ្ចប់វិវាទទាំងនេះចំណុំឱ្យសេរីភាពនៃឆន្ទៈរបស់ភាគីវិវាទ។ ការសម្រុះសម្រួលផ្សះផ្សាវិវាទនៅក្នុងក្របខ័ណ្ឌ **អ.ដ.ក.** មិនអាចធ្វើបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ លើកលែងតែច្បាប់អនុញ្ញាត។

ពាក្យបណ្តឹងដែល **អ.ដ.ក.** ទទួលយកមកពិនិត្យ និងសម្រុះសម្រួលដោះស្រាយ អាចជាពាក្យបណ្តឹងដែលទទួលផ្ទាល់ពីរូបបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់បណ្តឹង ឬអាចទទួលបានតាមរយៈការបញ្ជូនមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ **អ.ដ.ក.** ក៏អាចទទួលពិនិត្យ និងដោះស្រាយនូវសំណុំរឿងវិវាទដែលបញ្ជូនមកពី សាលាជម្រះក្តីជាន់ទាប ក្នុងករណីភាគីវិវាទណាមួយបានបង្ហាញឆន្ទៈឱ្យធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួន។ ការបញ្ជូនសំណុំរឿងពីតុលាការមក **អ.ដ.ក.** នេះ អាចធ្វើឡើងតាមសំណើរបស់ភាគីវិវាទទាំងសងខាង ឬតាមសំណើរបស់ភាគីណាមួយ។ ការសម្រេចលើការបញ្ជូននេះ គឺជា ឆន្ទានុសិទ្ធិរបស់ចៅក្រម។ ប៉ុន្តែ ដើម្បីចៀសវាងនូវស្ថានភាពនៃការអូសបន្លាយនីតិវិធីក្នុងការសម្រេចក្តីតាមរយៈការបញ្ជូនសំណុំរឿងមក**អ.ដ.ក.** ឬក្នុងករណីដែលភាគីយល់ឃើញថា ការដោះស្រាយដោយការសម្រុះសម្រួលគ្នានៅ**អ.ដ.ក.** មិនអាចប្រព្រឹត្តទៅបាន,ភាគីណាមួយនៃវិវាទមានសិទ្ធិស្នើសុំទៅតុលាការ ដើម្បីបន្តចំណាត់ការនីតិវិធីលើសំណុំរឿងវិវាទឡើងវិញ។ បែបបទ និងនីតិវិធីនៃការបញ្ជូនសំណុំរឿងវិវាទរវាងសាលាជម្រះក្តី និង **អ.ដ.ក.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ២- គោលការណ៍នៃការសម្រុះសម្រួលដោះស្រាយវិវាទដោយ អ.ជ.ក.

យោងតាមមាត្រា ១១ នៃព្រះរាជក្រឹត្យបង្កើត **អ.ជ.ក.**, ការដោះស្រាយវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវធ្វើឡើងតាមរយៈ**ការសម្រុះសម្រួលផ្សះផ្សា**។ ផ្អែកតាមមាត្រា១១ នេះ វិធីសាស្ត្រដោះស្រាយវិវាទរបស់ **អ.ជ.ក.** គឺមានទាំងវិធីសាស្ត្រ ការសម្រុះសម្រួល ទាំងវិធីសាស្ត្រ ការ**ផ្សះផ្សា**។ ក្នុងន័យនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទរបស់ **អ.ជ.ក.** ត្រូវដើរតួនាទីសកម្ម ទាំងលើការកំណត់អំពីចំណុចវិវាទ ការកំណត់អំពីការទាមទារ ក៏ដូចជាអាចផ្តល់នូវមតិជាការវាយតម្លៃអំពីវិវាទ ការស្នើនូវដំណោះស្រាយសម្រាប់បញ្ចប់វិវាទ ព្រមទាំងការផ្តល់យោបល់អំពីផលវិបាកដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទ។ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទជាអ្នកសម្រុះសម្រួលជួយផ្សះផ្សាវិវាទនិងជួយបំផុសនូវជម្រើសនៃដំណោះស្រាយដល់ភាគីវិវាទ ដោយត្រូវប្រកាន់នូវជំហរអព្យាក្រឹត និងមិនលំអៀង និងត្រូវផ្តល់ឱ្យភាគីវិវាទនូវឱកាសព្រមព្រៀងសះជាវិវាទដោយសន្តិវិធី និងដោយគ្មានការធ្វើសេចក្តីសម្រេចដោយបង្ខំណាមួយឡើយ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ គ្មានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចណាមួយជំនួសភាគីវិវាទបានឡើយ។នៅគ្រប់ករណីវាល់ដំណោះស្រាយចំពោះវិវាទត្រូវតែគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តរបស់ភាគីវិវាទ។ ភាគីវិវាទមានសិទ្ធិស្មើគ្នានៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួលវិវាទ។

នៅក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទនេះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលវិវាទ ឬសមាសភាព **អ.ជ.ក.** អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត, ណែនាំឱ្យភាគីវិវាទបញ្ជាក់ពីការទាមទារ ឬផ្តល់ព័ត៌មានបន្ថែមលើការទាមទារ ឬស្រាវជ្រាវព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងវិវាទដោយយោងតាមការចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ ការចូលរួមក្នុងកិច្ចដំណើរការនេះជាសិទ្ធិសេរីភាពរបស់ភាគី។ ក្នុងករណីដែលភាគីមិនព្រមចូលរួម មានន័យថាភាគីមិនយល់ព្រមធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួនឡើយ។ ក្នុងករណីដែលភាគីចូលរួម ភាគីវិវាទចូលរួមដោយផ្ទាល់ ឬភាគីអាចត្រូវបានតំណាងដោយអ្នកតំណាងដោយអាណត្តិ ឬអាចអមដោយមេធាវី ឬអ្នកប្រឹក្សាយោបល់របស់ខ្លួនតាមការចាំបាច់។ ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវធានាថា គ្រប់ភាគី និងបុគ្គលពាក់ព័ន្ធទទួលបាននូវព័ត៌មាន និងការពន្យល់បំភ្លឺយ៉ាងច្បាស់ និងត្រឹមត្រូវអំពីកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ សិទ្ធិរបស់ភាគី ការរក្សាការសម្ងាត់វិជ្ជាជីវៈ និងផលវិបាកនានាដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទជាពិសេសអានុភាពនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងករណីដែលភាគីវិវាទព្រមព្រៀងសះជាបញ្ចប់

វិវាទនឹងគ្នា។ បែបបទ និងនីតិវិធីនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃ អ.ជ.ក. ត្រូវកំណត់ដោយសេចក្ដីសម្រេច របស់ **អ.ជ.ក.**[11]។

ការសម្រុះសម្រួលផ្សះផ្សាយវិវាទក្នុងក្របខ័ណ្ឌអ.ជ.ក.អាចត្រូវធ្វើឡើងដោយៈ(១)-**មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ** ឬ (២)-**ក្រុមការងារសម្រុះសម្រួលវិវាទ** ឬដោយ (៣)- **អ.ជ.ក.** តែម្ដង។

- **មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក.៖** ដើម្បីអាចទទួលបានការចាត់តាំងពី **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក. ត្រូវទទួលបាននីតិសម្បទាពី អ.ជ.ក. ជាមុនសិន។ តើនរណាខ្លះអាចក្លាយជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.**? តើដើម្បីអាចក្លាយជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក. ត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ? មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** អាចត្រូវបានជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌ ឬពីក្នុងចំណោមសារការី មេធាវី និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងទៀត ឬបុគ្គលផ្សេងទៀតដែលមានជំនាញផ្នែកច្បាប់ ឬជំនាញពាក់ព័ន្ធនឹងការដោះស្រាយវិវាទ។ ការជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអ.ជ.ក.ធ្វើឡើងតាមរយៈការប្រឡងជ្រើសរើសដែលរៀបចំ ឡើងដោយ **អ.ជ.ក.**។ បន្ទាប់ពីត្រូវបានជ្រើសរើស, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលរៀចំដោយក្រសួងយុត្តិធម៌លើជំនាញច្បាប់ ជំនាញដោះស្រាយវិវាទ ក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិ[12]។ ក្រសួងយុត្តិធម៌បានប្រគល់សិទ្ធិក្នុងការបណ្ដុះបណ្ដាលនេះឱ្យទៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដោយត្រូវសហការជាមួយអគ្គលេខាធិការដ្ឋាននៃ**អ.ជ.ក.**។បន្ទាប់ពីទទួលបានជោគជ័យក្នុងការបណ្ដុះបណ្ដាលនេះ, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទទួលបាននូវវិញ្ញាបនបត្របណ្ដុះបណ្ដាលជំនាញសម្រុះសម្រួលដោះស្រាយវិវាទដែលចេញដោយក្រសួងយុត្តិធម៌។ បន្ទាប់មកមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលបានបញ្ចប់ការបណ្ដុះបណ្ដាលដោយជោគជ័យ ត្រូវដាក់ពាក្យ ស្នើសុំ និងត្រូវទទួលបាននីតិសម្បទាពី **អ.ជ.ក.** ជាមុនសិន ទើបអាចបំពេញមុខងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** បាន។

នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនេះ ក៏អាចត្រូវបានផ្ដល់ជូនបុគ្គលផ្សេងទៀតផងដែរ ជាអាទិ៍ អតីតចៅក្រម អតីតព្រះរាជអាជ្ញា អតីតក្រឡាបញ្ជី ឬអតីតអាជ្ញាសាលាដែលបានប្រកបវិជ្ជាជីវៈយ៉ាងតិច៣ឆ្នាំ, មេធាវីឬសារការីដែលបានប្រកបវិជ្ជាជីវៈរយៈពេលយ៉ាង

11. សេចក្ដីសម្រេចលេខ ០០២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីបែប និងនីតិវិធីនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃអាជ្ញាធរជាតិ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
12. សេចក្ដីសម្រេចលេខ ០០៦/២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ស្ដីពីក្រមសីលធម៌ និងក្រមប្រតិបត្តិសម្រាប់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

តិច ៣ ឆ្នាំ, សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬមជ្ឈត្តករដែលមានបទពិសោធន៍ការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរយៈពេលយ៉ាងតិច ៣ឆ្នាំ, ឥស្សរជន ឬមន្ត្រីសាធារណៈដែលមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទរយៈពេលយ៉ាងតិច ៣ ឆ្នាំ, បុគ្គលដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ និងបុគ្គលដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរយៈពេលយ៉ាងតិច៣ឆ្នាំ។ បែបបទនីតិវិធីនិងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ជ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ជ.ក.**[13]។ មុននឹងអនុវត្តមុខងាររបស់ខ្លួន ពោលគឺមុននឹងអាចធ្វើការសម្រុះសម្រួលដោះស្រាយវិវាទបានមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ជ.ក.** ដែលទទួលបាននីតិសម្បទា ត្រូវធ្វើសច្ចាប្រណិធានដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌។

-**ក្រុមការងារសម្រុះសម្រួលវិវាទ**៖ ការសម្រុះសម្រួលវិវាទក្នុងក្របខ័ណ្ឌ**អ.ជ.ក.** អាចធ្វើឡើងដោយក្រុមការងារសម្រុះសម្រួលវិវាទ។ ប្រធាន**អ.ជ.ក.** អាចបង្កើតក្រុមការងារសម្រុះសម្រួលវិវាទមួយចំនួនតាមការចាំបាច់ដោយសេចក្តីសម្រេចដើម្បីចុះទៅសម្រុះសម្រួលផ្សះផ្សាបញ្ចប់វិវាទដោយផ្ទាល់នៅតាមមូលដ្ឋាន ជាពិសេស បណ្តឹងដែលប្រជាពលរដ្ឋបានប្តឹងទៅការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានក្រុង-ស្រុក-ខណ្ឌ ឬប្តឹងទៅឃុំ-សង្កាត់នានា។ ក្រុមការងារសម្រុះសម្រួលវិវាទនេះ ចាំបាច់ត្រូវដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ជ.ក.** និងអាចមានសមាសភាពផ្សេងទៀតចូលរួម ដែលជាអ្នកជំនាញផ្នែកច្បាប់ ឬកិច្ចការសង្គម។ សមាសភាពផ្សេងទៀតនេះ អាចជាចាស់ព្រឹទ្ធាចារ្យ អាចារ្យវត្ត ឬប្រធានសហគមន៍ជនជាតិដើមភាគតិចជាដើម។ ការបង្កើតជាក្រុមការងារសម្រុះសម្រួលវិវាទនេះ មានភាពចាំបាច់នៅពេលដែល **អ.ជ.ក.** ចុះធ្វើការដោះស្រាយវិវាទផ្ទាល់នៅតាមមូលដ្ឋាន តាមសហគមន៍ជនជាតិដើមភាគតិចនៅតាមតំបន់ដាច់ស្រយាលនានា។ ប៉ុន្តែ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងច្បាស់លាស់ ជាពិសេស ក្នុងការរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលមានអានុភាពអនុវត្ត ក្រុមការងារនេះត្រូវតែដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងមាននីតិសម្បទាពី **អ.ជ.ក.**។

- **ការសម្រុះសម្រួលផ្សះផ្សាដោយ អ.ជ.ក.**៖ វិវាទដែលប្តឹងមក **អ.ជ.ក.** ក៏អាចត្រូវបានដោះស្រាយដោយផ្ទាល់ដោយ **អ.ជ.ក.** ក្រោមការដឹកនាំរបស់ប្រធាន **អ.ជ.ក.** អនុប្រធាន ឬសមាជិកណាមួយនៃ**អ.ជ.ក.** ផងដែរ។ ប្រធាន**អ.ជ.ក.** អាចចាត់តាំងសមាជិក**អ.ជ.ក.** ណាម្នាក់

13. សេចក្តីសម្រេចលេខ ០០២/២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីបែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអាជ្ញាជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ដើម្បីធ្វើជាតំណាងឱ្យ **អ.ជ.ក.** ក្នុងការទទួលពិនិត្យ និងសម្រុះសម្រួលដោះស្រាយវិវាទក្នុងនាម **អ.ជ.ក.**។ ការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ **អ.ជ.ក.** ត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដូចគ្នានឹងការសម្រុះសម្រួលផ្សះផ្សាវិវាទដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ផងដែរ។

## ៣-អានុភាពគតិយុត្តនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដោយ អ.ជ.ក.

ក្នុងករណីដែលការសម្រុះសម្រួលផ្សះផ្សាវិវាទទទួលបានជោគជ័យ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទឬសមាជិក**អ.ជ.ក.**ដែលទទួលបន្ទុកត្រូវរៀបចំចេញ **កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ**។ ក្នុងករណីដែលចំណុចវិវាទមានច្រើនហើយភាគីវិវាទព្រមព្រៀងគ្នាបញ្ចប់តែលើចំណុចមួយចំនួននោះ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ក៏អាចត្រូវបានធ្វើឡើងផងដែរ ប៉ុន្តែ ត្រូវធ្វើតែលើចំណុចវិវាទដែលភាគីបានព្រមព្រៀងគ្នាប៉ុណ្ណោះ។ ដោយឡែក ក្នុងករណីដែលការសម្រុះសម្រួលផ្សះផ្សាវិវាទ មិនទទួលបានជោគជ័យ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទឬសមាជិក **អ.ជ.ក.** ទទួលបន្ទុក ត្រូវរៀបចំជារបាយការណ៍ច្បាស់លាស់។ ចំពោះសំណុំរឿងដែលត្រូវបានបញ្ជូនមក អ.ជ.ក. ដោយសាលាជម្រះក្តីជាន់ទាប, ក្រោយបញ្ចប់ការសម្រុះសម្រួលផ្សះផ្សាវិវាទ, **អ.ជ.ក.** ត្រូវផ្ញើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ ទៅសាលាជម្រះក្តីដែលបានបញ្ជូនសំណុំរឿងវិវាទនោះមក អ.ជ.ក. ដោយភ្ជាប់ជាមួយនូវសំណុំរឿង និងឯកសារពាក់ព័ន្ធ។ ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបានដោយជោគជ័យដោយ **អ.ជ.ក.**, សាលាជម្រះក្តីត្រូវបន្តចំណាត់ការដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ បែបបទ នីតិវិធីលម្អិតនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** ព្រមទាំងទម្រង់បែបបទ និងខ្លឹមសារសំខាន់ៗនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវកំណត់ដោយ **អ.ជ.ក.**។

ភាគីដែលមិនសុខចិត្តនឹងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ មានសិទ្ធិប្តឹងតវ៉ាទៅ**អ.ជ.ក.** ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ។ ក្នុងករណីដែលមិនមានបណ្តឹងតវ៉ានោះទេ ឬក្នុងករណីដែលបណ្តឹងតវ៉ានេះ ត្រូវបានសម្រេចបដិសេធដោយ**អ.ជ.ក.** នោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ត្រូវចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលត្រូវបានធ្វើឡើងត្រឹមត្រូវ មានតម្លៃគតិយុត្តរឹងមាំ ដែលនេះជាលក្ខណៈពិសេសនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃអ.ជ.ក.បើធៀបទៅនឹងការដោះស្រាយវិវាទដោយយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងទៀត។ តើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះមានតម្លៃគតិយុត្តរឹងមាំយ៉ាងដូចម្តេច? តើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះមានអានុភាពគតិយុត្តយ៉ាងដូចម្តេចខ្លះ?

ផ្អែកតាមមាត្រា១៥ នៃព្រះរាជក្រឹត្យបង្កើត **អ.ដ.ក.** បានបញ្ញត្តថា កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌនៃ អ.ដ.ក. ដែលត្រូវបានធ្វើឡើងត្រឹមត្រូវ មានអានុភាពគតិយុត្តសំខាន់ៗ ចំនួន ២ គឺ៖

- កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ **មាន តម្លៃគតិយុត្តដូចលិខិតយថាភូត និងត្រូវចាត់ទុកជាបន្ទាល់** ដែលតុលាការត្រូវតែជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញពីការក្លែងបន្លំ ឬវិការៈដទៃទៀតនៅក្នុងកំណត់ហេតុនេះ។ មានន័យថា ប្រសិនបើគ្មានការក្លែងបន្លំ ឬគ្មានវិការៈនៃការព្រមព្រៀងនោះទេ, កំណត់ហេតុនេះមានតម្លៃជាភស្តុតាងរឹងមាំដែលភាគីមិនអាចកែប្រែ ឬប្រកែកបានឡើយនៅចំពោះមុខតុលាការ។

- កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ **មាន អានុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពរ** របស់តុលាការ និងត្រូវចាត់ទុកជា **លិខិតអនុវត្ត** ដូចមានចែងក្នុងចំណុច ឈ នៃកថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្នុងន័យនេះ ក្នុងករណីដែលមានភាគីណាមិនព្រមអនុវត្តដោយស្ម័គ្រចិត្តតាមខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ, ភាគីវិវាទអាចស្នើសុំអនុវត្តកំណត់ហេតុនេះ ដោយអនុវត្តស្របតាមនីតិវិធីច្បាប់ជាធរមាន។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬសមាជិក **អ.ដ.ក.** ដែលចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ជាអ្នកផ្តល់រូបមន្តអនុវត្តចំពោះកំណត់ហេតុនេះ តាមការស្នើសុំ។ ការកំណត់បែបនេះ គឺផ្អែកលើមូលដ្ឋាននៃមាត្រា ៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងថា រូបមន្តអនុវត្ត ត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះ តាមពាក្យសុំ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ច នៃកថាខណ្ឌទី២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ (*សំដៅដល់លិខិតយថាភូតដែលធ្វើឡើងសារការី*) ត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ។ ហេតុដូចនេះ ដោយកំណត់ហេតុព្រមព្រៀមបញ្ចប់វិវាទរបស់ **អ.ដ.ក.** មានតម្លៃដូចជាលិខិតយថាភូត និងសាលាក្រមស្ថាពរ, រូបមន្តអនុវត្តចំពោះកំណត់ហេតុនេះត្រូវផ្តល់ដោយអ្នកដែលធ្វើកំណត់ហេតុនោះពោលគឺដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬសមាជិក **អ.ដ.ក.** ទទួលបន្ទុក។ ម្យ៉ាងទៀត **អ.ដ.ក.** ត្រូវចាត់នីតិវិធីចាំបាច់នានាដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះផងដែរ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញសេចក្តីណែនាំដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ។

ផ្អែកលើអានុភាពគតិយុត្តទាំងនេះជាគោលការណ៍ភាគីពាក់ព័ន្ធមិនអាចប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីសើរើចំពោះកំណត់ហេតុនេះបាននោះទេ លើកលែងតែ ក្នុងករណីដូចខាងក្រោម៖

- មានភស្តុតាងដែលបង្ហាញពីការក្លែងបន្លំ ឬវិការៈផ្សេងទៀតនៅក្នុងកំណត់ហេតុនេះ។

-ខ្លឹមសារនៃកំណត់ហេតុនេះផ្ទុយនឹងបទប្បញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា[14]។

- កំណត់ហេតុនេះ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជន។ ក្នុងករណីនេះ តតិយជនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ដែលអាចជាបណ្តឹងតវ៉ារបស់តតិយជនចំពោះការអនុវត្ត និង/ឬ ជាបណ្តឹងទាមទាររបស់តតិយជន។

ការកំណត់ឱ្យកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ មានតម្លៃជាបន្ទាល់ ជាលិខិតអនុវត្ត និងមានអានុភាពអនុវត្តដូចសាលក្រមស្ថាពរ ក៏ដូចជា កំណត់នូវលក្ខខណ្ឌតឹងរឹងសម្រាប់ការប្តឹងសើរើចំពោះវិវាទដែលបានដោះស្រាយបញ្ចប់ដោយជោគជ័យដោយ អ.ជ.ក. នេះ គឺធ្វើឡើងដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់នៃការសម្រុះសម្រួលវិវាទក្នុងក្របខ័ណ្ឌអ.ជ.ក. និងធានាថាវិវាទដែលបានសម្រុះសម្រួលផ្សះផ្សាដោយជោគជ័យដោយអ.ជ.ក.ត្រូវបានដោះស្រាយចប់ជាស្ថាពរតែម្តង។

ទន្ទឹមនេះ ផ្អែកតាមអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទជាមួយ **អ.ជ.ក.**, ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ អាចស្នើសុំមក **អ.ជ.ក.** ដើម្បីទទួលស្គាល់ការសម្រុះសម្រួលវិវាទព្រមទាំងពិនិត្យនិងរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ចំពោះវិវាទដែលត្រូវបានសម្រុះសម្រួលបញ្ចប់ក្នុងក្របខ័ណ្ឌស្ថាប័នរបស់ខ្លួន។ បច្ចុប្បន្ន **អ.ជ.ក.**បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការនេះជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ តាមរយៈអនុស្សរណៈនៃការយោគយោល់គ្នានេះ វិវាទដែលត្រូវបានសម្រុះសម្រួលបញ្ចប់ដោយមេធាវី ឬដោយមជ្ឈត្តករ ក៏អាចជាកម្មវត្ថុនៃការធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** ដែលមានតម្លៃគតិយុត្តដូចគ្នានឹងការសម្រុះសម្រួលផ្សះផ្សាវិវាទដែលធ្វើឡើងដោយផ្ទាល់ដោយ **អ.ជ.ក.** សំដៅឈានទៅបញ្ចប់វិវាទនេះជាស្ថាពរបានផងដែរនេះ។ ក្នុងន័យនេះ បន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់ **អ.ជ.ក.**, ទាំងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទាំងមេធាវី ទាំងមជ្ឈត្តករ នឹងក្លាយជាភ្នាក់ងារដ៏សំខាន់ក្នុងការពន្លត់ភ្លើងវិវាទនៅក្នុងសង្គមដោយមិនទុកឱ្យវិវាទ

14.យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៩ ចំណុច គ, សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានកំណត់ថាជាលក្ខខណ្ឌសម្រាប់បដិសេធមិនទទួលស្គាល់អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស។ សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែ “ខ្លឹមសារនៃសាលក្រម និងនីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា”។ ទន្ទឹមនេះ មាត្រា៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី៤ បានបញ្ញត្តផងដែរថា តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករ ប្រសិនបើយល់ឃើញថា ការទទួលស្គាល់ ឬការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ។

ក្លាយទៅជាវិវាទរ៉ាំរ៉ៃពិបាកដោះស្រាយ ដែលការណ៍នេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងអនុវត្តឱ្យបាន ជោគជ័យនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងវិធានការគន្លឹះ ជាអាទិភាពរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៕